# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥០៣៨....សហវ.ប្រក

## ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩២ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០២៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១៥ ស្ដីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៦ ស្ដីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៥៤៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៣ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានក្រោមឱវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

**ប្រការ២.-**

ប្រកាសនេះមានគោលបំណងរៀបចំមុខងារ និងភារកិច្ចរបស់នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ក្រោមឱវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

**ប្រការ៣.-**

នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង លើការងារសវនកម្មបច្ចេកវិទ្យាព័ត៌មាន នៅតាមអង្គភាពថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤.-**

នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានមានភារកិច្ចដូចតទៅ:

- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យានៃអគ្គនាយកដ្ឋាន
- រៀបចំគោលការណ៍ ស្តង់ដា និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋាន
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ជំនាញសវនកម្មបច្ចេកវិទ្យាព័ត៌មានរយៈពេលវែង មធ្យម និងខ្លី
- រៀបចំគោលការណ៍ ស្តង់ដា និងនីតិវិធីអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មាន
- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម និងផែនការសវនកម្មប្រចាំឆ្នាំនៃអគ្គនាយកដ្ឋាន
- ធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអង្គភាពទាំងឡាយក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន និងតាមដានការអនុវត្តអនុសាសន៍
- ធ្វើសវនកម្មលើប្រព័ន្ធ FMIS នៅអង្គភាពទាំងឡាយក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន និងតាមដានការអនុវត្តអនុសាសន៍សវនកម្ម

- រៀបចំរបាយការណ៍សវនកម្មបច្ចេកវិទ្យាព័ត៌មានសង្ខេប និងសរុបប្រចាំឆ្នាំជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន
- គ្រប់គ្រង និងរក្សាផ្នែករឹង និងទន់នៃបច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើការងារទូទៅ និងការងារសវនកម្ម
- ដោះស្រាយបញ្ហាបច្ចេកវិទ្យាព័ត៌មានប្រចាំថ្ងៃ និងអភិវឌ្ឍប្រព័ន្ធការពារ ថតបម្រុងទិន្នន័យ និងព័ត៌មាន និងកិច្ចការសន្តិសុខ និងសុវត្ថិភាពប្រព័ន្ធ
- ពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានជាប្រចាំតាមរយៈការស្រាវជ្រាវ ការប្រមូលព័ត៌មាន ការផ្លាស់ប្តូរបទពិសោធន៍ និងការហ្វឹកហ្វឺនក្នុង និងក្រៅប្រទេស ព្រមទាំងទាក់ទាញជំនួយបច្ចេកទេសផ្នែកបច្ចេកវិទ្យាព័ត៌មាន
- រៀបចំកម្មវិធីបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី លើការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងផ្នែកសវនកម្មបច្ចេកវិទ្យាព័ត៌មានជូនមន្ត្រីក្នុងអគ្គនាយកដ្ឋាន និងសវនករតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ
- ជំរុញការធ្វើស្វ័យប្រវត្តកម្មការងារសវនកម្ម និងមិនមែនសវនកម្មក្នុងអគ្គនាយកដ្ឋាន
- គ្រប់គ្រង និងអភិវឌ្ឍគេហទំព័រ បណ្តាញផ្ទៃក្នុង និងកុំព្យូទ័របម្រើរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងបណ្តាញភ្ជាប់ទៅប្រព័ន្ធ FMIS និងប្រព័ន្ធដទៃទៀតរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់គ្រង និងចងក្រងមូលដ្ឋានទិន្នន័យ និងឯកសារសវនកម្មក្នុងម៉ាស៊ីនបម្រើរបស់អគ្គនាយកដ្ឋាន
- វិភាគមុខងារ និងតម្រូវការបច្ចេកវិទ្យាព័ត៌មានតាមនាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋាន
- សហការបំពេញការងារពាក់ព័ន្ធបច្ចេកវិទ្យាព័ត៌មានជាមួយនាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានគោល-នយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងអង្គភាពនានាក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកសាង អនុវត្ត តាមដាន និងរាយការណ៍លើផែនការសកម្មភាព របស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងតាមការបែងចែកពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់នានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមរៀបចំរបាយការណ៍សកម្មភាព និងផែនការការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- អនុវត្តរាល់ការងារនិងភារកិច្ចផ្សេងទៀតដែលអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងប្រគល់ជូន។

**ប្រការ៥.-**

នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានការិយាល័យក្រោមឱវាទចំនួនពីរដូចខាងក្រោម÷

១. ការិយាល័យសវនកម្មបច្ចេកវិទ្យាព័ត៌មានថ្នាក់កណ្តាល

២. ការិយាល័យសវនកម្មបច្ចេកវិទ្យាព័ត៌មានថ្នាក់មូលដ្ឋាន។

ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៦.-**

ការិយាល័យសវនកម្មបច្ចេកវិទ្យាព័ត៌មានថ្នាក់កណ្តាល បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន និងមានភារកិច្ចដូចតទៅ:

- ចូលរួមរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យានៃអគ្គនាយកដ្ឋាន

- រៀបចំរបាយការណ៍សកម្មភាព និងផែនការការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនថ្នាក់ដឹកនាំនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងទៀត ដែលអគ្គនាយកដ្ឋាន និងនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានប្រគល់ជូន។

**ប្រការ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងនាយកវិទ្យាស្ថាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

***កន្លែងទទួល:***

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ